ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

# កម្មវិធីពិសេសជំរុញការវិនិយោគ
# ក្នុងខេត្តព្រះសីហនុ ឆ្នាំ ២០២៤

ខែ មករា ឆ្នាំ ២០២៤

## ១. សេចក្តីផ្តើម

ប្រទេសកម្ពុជាសម្រេចបានសន្តិភាពពេញលេញ និង ស្ថិរភាព ព្រមទាំងការអភិវឌ្ឍលើគ្រប់វិស័យ ដែលជាសមិទ្ធផលដ៏ធំធេង កើតចេញពីការប្តេជ្ញាចិត្តខ្ពស់ និង កិច្ចខិតខំប្រឹងប្រែងក្នុងការដាក់ចេញ និង ការអនុវត្តដោយជោគជ័យនូវយុទ្ធសាស្ត្រ គោលនយោបាយ និង កម្មវិធីនានារបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ប៉ិនប្រសប់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ។ ជាមួយនេះ, រាជរដ្ឋាភិបាល ក្នុងនីតិកាលទី ៧ នៃរដ្ឋសភា កំពុងបន្តដឹកនាំប្រទេសជាតិ ឆ្ពោះទៅរកវឌ្ឍនភាព និង បង្កើតសមិទ្ធផលថ្មីៗបន្ថែម តាមគោលការណ៍ **"រក្សាចាស់ ពង្រីកថ្មី"** ដោយពង្រឹងការអនុវត្តប្រកបដោយប្រសិទ្ធភាព និង ពង្រីកវិសាលភាពនៃការអនុវត្ត, តាមរយៈការដាក់ចេញបន្ថែមនូវយុទ្ធសាស្ត្រ គោលនយោបាយ និង កម្មវិធីសំខាន់ៗ ដើម្បីឆ្លើយតបទៅនឹងស្ថានភាព និង និន្នាការថ្មីក្នុងសកលលោក តំបន់ និង ក្នុងប្រទេស ព្រមទាំងដោះស្រាយបញ្ហាប្រឈមនានា បានទាន់ពេល និង ចំគោលដៅ សម្រាប់ស្តារ និង/ឬ ជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។

ជាលទ្ធផលនៃការគ្រប់គ្រងប្រកបដោយភាពវៃឆ្លាត និង បុរេសកម្មរបស់រាជរដ្ឋាភិបាលកន្លងមក, កម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ នៅក្នុងរង្វង់ ៧% និង មានលទ្ធភាពត្រឡប់ទៅរកកំណើនខ្ពស់វិញ បន្ទាប់ពីវិបត្តិជំងឺកូវីដ-១៩ បានថមថយ ។ រចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជាមានពិពិធកម្មជាបន្តបន្ទាប់ ពីសេដ្ឋកិច្ចដែលពឹងផ្អែកខ្លាំងទៅលើវិស័យកសិកម្ម មកសេដ្ឋកិច្ចដែលពឹងផ្អែកជាសំខាន់លើវិស័យឧស្សាហកម្ម ដែលបច្ចុប្បន្នកម្ពុជាកំពុងធ្វើបរិវត្តកម្ម ឆ្ពោះទៅរកឧស្សាហកម្ម ដែលមានតម្លៃបន្ថែមខ្ពស់ជាងមុន ដូចជា ការកែច្នៃ, អេឡិចត្រូនិក, ការផ្គុំ, ផលិតកម្មក្រៅពីលោហៈ និង ផលិតកម្មប្រើបច្ចេកវិទ្យាមធ្យម ។

ដោយផ្អែកលើតម្រូវការចាំបាច់ជាក់ស្តែង និង ការសម្លឹងទៅមុខរយៈពេលវែង, រាជរដ្ឋាភិបាលបានដាក់ចេញ **"យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១"** សំដៅកសាងមូលដ្ឋាន ឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០ ។ ជាការពិត, យុទ្ធសាស្ត្របញ្ចកោណជារបៀបវារៈ ក្នុងការជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចគ្រប់វិស័យ ។ នៅក្នុងយុទ្ធសាស្ត្រនេះ រាជរដ្ឋាភិបាលក៏បានគិតគូរដល់ការជំរុញការអភិវឌ្ឍវិស័យ ឬ តំបន់ជាពិសេស ក្នុងន័យប្រែក្លាយវិស័យ ឬ តំបន់នោះ ឱ្យក្លាយជាក្បាលម៉ាស៊ីនអូសទាញកំណើនជារួម ។ ក្នុងន័យនេះ, មុំទី១ **"ការអភិវឌ្ឍវិស័យគន្លឹះ និង ប្រភពថ្មីនៃកំណើនសេដ្ឋកិច្ច"** នៃបញ្ចកោណទី ២ **"ការធ្វើពិពិធកម្មសេដ្ឋកិច្ច និង ការបង្កើនភាពប្រកួតប្រជែង"** បានដាក់ចេញជាអាទិភាពក្នុងការពន្លឿនការអភិវឌ្ឍខេត្តព្រះសីហនុ ឱ្យក្លាយទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង និង ជាប៉ូលសេដ្ឋកិច្ចដ៏សំខាន់ ក្នុងការជំរុញកំណើនសេដ្ឋកិច្ចសម្រាប់កម្ពុជា ។

ខេត្តព្រះសីហនុ ជាខេត្តមានសក្តានុពលខ្ពស់ ក្នុងការទាក់ទាញការវិនិយោគ ដោយខេត្តមានទីតាំងអំណោយផល ក្នុងការអភិវឌ្ឍវិស័យទេសចរណ៍, មានហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ជាអាទិ៍ កំពង់ផែសមុទ្រទឹកជ្រៅ, ព្រលានយន្តហោះ, ផ្លូវល្បឿនលឿន ដើម្បីបម្រើដល់ការវិនិយោគ និង មានតំបន់សេដ្ឋកិច្ចពិសេសធំៗមួយចំនួនរួចហើយ ។ ជាការពិត, ខេត្តព្រះសីហនុបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់កម្ពុជា នាពេលកន្លងមក ។ ទោះបីជាយ៉ាងនេះក្តី, ខេត្តព្រះសីហនុក៏នៅមានបញ្ហាប្រឈមមួយចំនួន ដែលតម្រូវឱ្យរាជរដ្ឋាភិបាលមានការគិតគូរ និង ដោះស្រាយ ដូចជា ការសាងសង់អគារជាច្រើន



តេឡេក្រាម ឯកសារមន្ត្រីសាធារណៈ - https://t.me/oa_channel

មិនទាន់បានបញ្ចប់ ឬ បានបញ្ចប់ តែពុំអាចប្រកបអាជីវកម្មបាន (អគារជាប់គាំង), តម្រូវការហេដ្ឋារចនាសម្ព័ន្ធបន្ថែម និង ការសម្របសម្រួលក្នុងការទាក់ទាញការវិនិយោគ ។ ដើម្បីសម្រេចបាននូវគោលដៅខាងលើ, ប្រើប្រាស់ឱ្យអស់នូវសក្តានុពល និង ដោះស្រាយបញ្ហាប្រឈមនានារបស់ខេត្តព្រះសីហនុ ប្រកបដោយប្រសិទ្ធភាព, រាជរដ្ឋាភិបាលសម្រេចដាក់ចេញ **កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ ឆ្នាំ ២០២៤** ។ កម្មវិធីពិសេសនេះ ជាគំនិតផ្តួចផ្តើមថ្មីមួយទៀតរបស់រាជរដ្ឋាភិបាល ដែលត្រូវបានប្រសិទ្ធនាម "**វិនិយោគក្នុងខេត្តព្រះសីហនុ ឆ្នាំ ២០២៤**" ។

កម្មវិធីពិសេសនេះឈរលើទស្សនាទានរួមចំនួន ៤ រួមមាន **ទី១.** កែប្រែមុខមាត់ខេត្តព្រះសីហនុ ឱ្យទៅជាខេត្តដែលមានមូលដ្ឋានសេដ្ឋកិច្ចពឹងផ្អែកលើ ឧស្សាហកម្ម ទេសចរណ៍ និង ការវិនិយោគ, **ទី២.** ដោះស្រាយបញ្ហាប្រឈមជាក់ស្តែងដែលនាំមកនូវលទ្ធផលឆាប់រហ័ស, **ទី៣.** បំពេញបន្ថែម និង ធ្វើឱ្យមានសង្គតិភាពជាមួយយុទ្ធសាស្ត្រ និង ផែនការក្នុងវិស័យផ្សេងៗ ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល និង **ទី៤.** បង្កើនល្បឿននៃការធ្វើបរិវត្តកម្ម និង ការអភិវឌ្ឍឧស្សាហកម្ម ក្នុងខេត្តព្រះសីហនុ ឱ្យមានតម្លៃបន្ថែម ផលិតភាពខ្ពស់ និង ឧត្តមភាពប្រកួតប្រជែង ។ កម្មវិធីពិសេសនេះមានគោលបំណងជំរុញឱ្យមានសកម្មភាពវិនិយោគ និង ធុរកិច្ចកាន់តែច្រើន និង មានសន្ទុះលឿន ក្នុងខេត្តព្រះសីហនុសម្រាប់ឆ្នាំ ២០២៤ ។

## ២. វិសាលភាព និង វិធានការ

**កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ ឆ្នាំ ២០២៤** ដាក់ចេញនូវវិធានការ និង យន្តការ ដែលមានលក្ខណៈជាកញ្ចប់, ប្រទាក់ក្រឡា, មុតស្រួច, និង សាមញ្ញ ។ វិធានការគន្លឹះៗ ក្នុងកម្មវិធីពិសេសនេះ មានភាពប្រទាក់ក្រឡាគ្នា និង ឆ្លើយតបនឹងស្ថានភាព និង តម្រូវការជាក់ស្តែងចំពោះមុខរបស់ខេត្តព្រះសីហនុ ក្នុងគោលដៅជំរុញការវិនិយោគ, ការអភិវឌ្ឍឧស្សាហកម្ម, ការស្តារកំណើនសេដ្ឋកិច្ច និង ការបំពេញបន្ថែមលើ យុទ្ធសាស្ត្រ និង គោលនយោបាយនានារបស់រាជរដ្ឋាភិបាល, ពិសេស ការអនុវត្តផែនការមេ ប្រែក្លាយខេត្តព្រះសីហនុ ទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ។

កម្មវិធីពិសេសនេះ ត្រូវអនុវត្តចំពោះគម្រោងវិនិយោគ ឬ សកម្មភាពធុរកិច្ច ក្នុងឆ្នាំ ២០២៤ ដែលមានទីតាំងនៅខេត្តព្រះសីហនុ និង ផ្តោតលើគម្រោង ៣ ប្រភេទ ដូចខាងក្រោម៖

(១) គម្រោងវិនិយោគ ឬ សកម្មភាពធុរកិច្ច ពាក់ព័ន្ធនឹងអគារកំពុងជាប់គាំង និង ចាប់ផ្តើមដំណើរការអនុវត្ត នៅក្នុងឆ្នាំ ២០២៤

(២) គម្រោងវិនិយោគ ឬ សកម្មភាពធុរកិច្ចមិនជាប់ពាក់ព័ន្ធនឹងអគារជាប់គាំង តែចាប់ផ្តើមដំណើរការបានភ្លាមនៅក្នុងឆ្នាំ ២០២៤

(៣) ការពង្រីកគម្រោងវិនិយោគ ឬ សកម្មភាពធុរកិច្ចមានស្រាប់ ស្របតាមលក្ខណៈវិនិច្ឆ័យជាក់លាក់ ដែលត្រូវចាប់ផ្តើមដំណើរការ នៅក្នុងឆ្នាំ ២០២៤ ។

ចំពោះគម្រោងវិនិយោគធំៗ, គម្រោងវិនិយោគដែលមានវេទយិតភាព និង គម្រោង ឬ សកម្មភាពវិនិយោគ និង ធុរកិច្ចផ្សេងទៀត ដែលស្ថិតនៅក្រៅវិសាលភាពនៃកម្មវិធីពិសេសនេះ ត្រូវដំណើរការតាមយន្តការជាធរមានរបស់រាជរដ្ឋាភិបាល ។ ជាមួយនេះ, ការលើកទឹកចិត្តផ្នែកពន្ធដារក្រោមកម្មវិធីពិសេសនេះ

មិនត្រូវអនុវត្តទេ ចំពោះសកម្មភាពវិនិយោគ និង ធុរកិច្ចក្នុងវិស័យធនាគារ និង ហិរញ្ញវត្ថុ និង កម្មន្តសាលកេសជ្ជៈ (លើកលែងតែកម្មន្តសាលកេសជ្ជៈ ធ្វើពីផលិតផលកសិកម្ម) ។

## ក. គម្រោងវិនិយោគពាក់ព័ន្ធនឹងអគារកំពុងជាប់គាំង

កន្លងមក, រាជរដ្ឋាភិបាលបានដាក់ចេញវិធានការជាកញ្ចប់ ដើម្បីដោះស្រាយគម្រោងវិនិយោគជាប់គាំងក្នុងខេត្តព្រះសីហនុ, ពោលគឺគម្រោងវិនិយោគនានា ដែលបានសាងសង់ ហើយបានផ្អាក, ពន្យារ ឬ បញ្ឈប់ការសាងសង់ និង/ឬ ពុំមានសកម្មភាពវិនិយោគ ឬ ធុរកិច្ច ក្នុងខេត្តព្រះសីហនុ ចាប់ពីឆ្នាំ ២០១៦ ។ យោងតាមបទពិសោធន៍ក្នុងការអនុវត្ត, វិធានការនេះ បានផ្តល់សញ្ញាវិជ្ជមាន និង បង្កើនជំនឿទុកចិត្តដល់វិនិយោគិន, ប៉ុន្តែ បានកម្រិតត្រឹមគម្រោងវិនិយោគជាប់គាំង, ខណៈដែលសកម្មភាពវិនិយោគ និង ធុរកិច្ចកំពុងជួបប្រទះបញ្ហាប្រឈម ដូចជា ការបង់ពន្ធអាករ និង កម្រៃផ្សេងៗច្រើន, សំណង់សាងសង់ពុំមាន ឬ ខុសលិខិតអនុញ្ញាតសាងសង់ និង ការសាងសង់ពុំមានការត្រួតពិនិត្យគុណភាព និង សុវត្ថិភាព, ការកំណត់តម្លៃអចលនទ្រព្យខ្ពស់, កង្វះទុនវិនិយោគបន្ថែម និង វិវាទរវាងម្ចាស់សំណង់ និង ម្ចាស់ដី ជាដើម ។ ក្នុង-ន័យនេះ, រាជរដ្ឋាភិបាលពិតជាមានភាពចាំបាច់ក្នុងការដាក់ចេញនូវវិធានការបន្ថែម ដើម្បីជំរុញឱ្យមានការវិនិយោគទៅលើអគារទាំងនោះ តាមរយៈការដាក់ចេញនូវវិធានការ ដូចខាងក្រោម៖

- លើកលែងពន្ធលើប្រាក់ចំណូល, ប្រាក់រំដោះពន្ធលើប្រាក់ចំណូល និង ពន្ធអប្បបរមា រយៈពេល ៣ ឆ្នាំ បន្ថែម សម្រាប់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (គ.ល.គ) និង សហ-គ្រាសធុនតូច និង មធ្យម ដែលបានចុះបញ្ជីពន្ធដារ
- លើកលែងពន្ធលើប្រាក់ចំណូលរយៈពេល ៣ ឆ្នាំ, ពន្ធអប្បបរមារយៈពេល ៣ ឆ្នាំ និង ប្រាក់-រំដោះពន្ធលើប្រាក់ចំណូល រយៈពេល ៣ ឆ្នាំ សម្រាប់គម្រោងវិនិយោគ ឬ សកម្មភាពធុរកិច្ចនានា ដែលពុំស្ថិតក្រោមច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- លើកលែងអាករលើតម្លៃបន្ថែម តាមអត្រាសូន្យភាគរយ ចំពោះសហគ្រាសតាមរបបស្វ័យ-ប្រកាសដែលផ្គត់ផ្គង់ក្នុងស្រុកនូវទំនិញ ឬ សេវាដល់គម្រោង ឬ សកម្មភាពធុរកិច្ចជាប់គាំងក្នុងខេត្តព្រះសីហនុ ក្នុងការសាងសង់បញ្ចប់ និង ការជួសជុលកែលម្អលើអគារដែលជាប់គាំង
- លើកលែងពន្ធកាត់ទុក លើការជួលអចលនទ្រព្យ រយៈពេល ៥ ឆ្នាំ
- លើកលែងពន្ធអចលនទ្រព្យ និង លើកលែងទណ្ឌកម្មរដ្ឋបាល (ពន្ធបន្ថែម និង ការប្រាក់) ចាប់ពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២៥ ហើយការលើកលែងនេះពុំមានអានុភាពប្រតិសកម្មចំពោះប្រាក់ពន្ធ រួមទាំងទណ្ឌកម្មរដ្ឋបាល (ពន្ធបន្ថែម និង ការប្រាក់) ដែលបានបង់រួចហើយនោះទេ
- លើកលែងការបង់ថ្លៃសេវាសាធារណៈ និង ថ្លៃលើសសន្ទស្សន៍ប្រើប្រាស់ដី ចំពោះការស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ លិខិតបិទការដ្ឋានសំណង់ ឬ វិញ្ញាបនបត្រប្រើប្រាស់សំណង់

- សម្រួលនីតិវិធី និង បែបបទនៃការស្នើសុំលិខិតអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ពាក់ព័ន្ធនឹងការងារសំណង់ រួមទាំងកាត់បន្ថយរយៈពេលនៃការស្នើសុំលិខិតអនុញ្ញាត ឬ វិញ្ញាបនបត្រប្រើប្រាស់សំណង់
- សម្របសម្រួលក្នុងការផ្តល់ការអនុគ្រោះលើថ្លៃត្រួតពិនិត្យ និង បញ្ជាក់គម្រោងប្លង់ស្ថាបត្យកម្ម ប្លង់គ្រឿងផ្គុំសំណង់ និង ថ្លៃត្រួតពិនិត្យ និង បញ្ជាក់គុណភាព និង សុវត្ថិភាពសំណង់ ដោយសហការជាមួយក្រសួង ស្ថាប័ន វិស័យឯកជន ម្ចាស់ដី និង ម្ចាស់សំណង់
- សម្រួលបែបបទ និង នីតិវិធីវិនិយោគ និង ធុរកិច្ច រួមទាំងការស្នើសុំអាជ្ញាបណ្ណ វិញ្ញាបនបត្រ និង លិខិតអនុញ្ញាតនានា ព្រមទាំងការចុះបញ្ជីជា គ.ល.គ និង សហគ្រាស
- រៀបចំគោលការណ៍ និង សម្របសម្រួលការបង្កើតទីផ្សារលក់ខ្សែឡុងអចលនទ្រព្យ និង ផ្តល់សេវាផ្គូផ្គងវិនិយោគិន រួមទាំងកំណត់តម្លៃយោង (reference price) សម្រាប់អចលនទ្រព្យក្នុងខេត្តព្រះសីហនុ
- រៀបចំតំបន់គម្រោងវិនិយោគ និង/ឬ តំបន់អភិវឌ្ឍ នៅតាមភូមិ សង្កាត់ និង ផ្លូវសំខាន់ៗ ដូចជា តំបន់ទេសចរណ៍ពិសិដ្ឋ តំបន់លក់ទំនិញរួចពន្ធដែលគ្រប់ជាតិសាសន៍អាចទិញទំនិញបាន វិថីអាហារ និង រមណីយដ្ឋាន/កន្លែងកម្សាន្ត ជាដើម ជាជំហានៗ ស្របតាមសក្តានុពល និង ភូមិសាស្ត្រជាក់ស្តែង
- ជំរុញការប្រើប្រាស់យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ស្របតាមបទប្បញ្ញត្តិច្បាប់ចំពោះវិវាទដែលពាក់ព័ន្ធនឹងការវិនិយោគ ។

## ខ. គម្រោងវិនិយោគ ដែលអាចចាប់ផ្តើមអនុវត្តបាននៅឆ្នាំ ២០២៤

រាជរដ្ឋាភិបាលបានដាក់ចេញគោលនយោបាយ និង យុទ្ធសាស្ត្រ រួមទាំងលិខិតបទដ្ឋាន និង កិច្ចព្រមព្រៀងនានា ដើម្បីទាក់ទាញការវិនិយោគជារួម នៅទូទាំងប្រទេស ខណៈដែលរាជរដ្ឋាភិបាលបានផ្តោតអាទិភាពខ្ពស់លើការអភិវឌ្ឍខេត្តព្រះសីហនុ ។ ការទាក់ទាញការវិនិយោគក្នុងខេត្តព្រះសីហនុ នឹងចូលរួមចំណែកយ៉ាងសំខាន់ ក្នុងការគាំទ្រ និង ការជំរុញសកម្មភាពវិនិយោគឡើងវិញ, ទាំងលើអគារជាប់គាំង និង សកម្មភាពធុរកិច្ចផ្សេងទៀត ។ សម្រាប់ឆ្នាំ ២០២៤, រាជរដ្ឋាភិបាលដាក់ចេញវិធានការគន្លឹះៗ ដើម្បីជំរុញការអនុវត្តគម្រោងវិនិយោគ ឬ សកម្មភាពធុរកិច្ច ដែលអាចចាប់ផ្តើមភ្លាមក្នុងខេត្តព្រះសីហនុ រួមទាំងវិធានការទាក់ទាញការវិនិយោគសំខាន់ៗ ដើម្បីបំពេញគ្នា ជាមួយវិធានការផ្សេងទៀត ដែលរួមមានជាអាទិ៍ ការសម្រួលនីតិវិធី និង ការលើកទឹកចិត្តវិនិយោគ និង ធុរកិច្ច, រំហូរវិនិយោគិន និង ទេសចរ, និង ការធានាសន្តិសុខ និង សុវត្ថិភាព ព្រមទាំងការកសាង និង ពង្រឹងកិត្តិនាមរបស់ខេត្តព្រះសីហនុ ។

ក្នុងន័យនេះ, រាជរដ្ឋាភិបាលដាក់ចេញវិធានការ ដូចខាងក្រោម៖

- សម្រួលបែបបទ និង នីតិវិធីវិនិយោគ និង ធុរកិច្ច រួមទាំងការស្នើសុំអាជ្ញាបណ្ណ វិញ្ញាបនបត្រ និង លិខិតអនុញ្ញាតនានា ព្រមទាំងការចុះបញ្ជីជា គ.ល.គ និង សហគ្រាស

- ផ្តល់ការលើកទឹកចិត្តពិសេស និង ការអនុគ្រោះនានា ដូចជា ពន្ធអាករនាំចូល ពន្ធប៉ាតង់ ពន្ធលើផ្ទាំងផ្សព្វផ្សាយ, ពន្ធកាត់ទុកលើការជួលអចលនទ្រព្យ និង កម្រៃសេវាចុះបញ្ជី ជាដើម ដល់សហគ្រាសដែលមកវិនិយោគ ឬ ធ្វើធុរកិច្ច ក្នុងខេត្តព្រះសីហនុ
- ផ្តល់ការលើកទឹកចិត្តលើកលែងពន្ធលើប្រាក់ចំណូល, ប្រាក់រំដោះពន្ធលើប្រាក់ចំណូល និង ពន្ធអប្បបរមា រយៈពេល ៣ ឆ្នាំ បន្ថែម សម្រាប់ គ.ល.គ និង សហគ្រាសធុនតូច និង មធ្យម ដែលបានចុះបញ្ជីពន្ធដារ
- អនុញ្ញាតឱ្យអនុវត្តអាករលើតម្លៃបន្ថែមអត្រាសូន្យភាគរយ សម្រាប់សហគ្រាសធុនតូច និង មធ្យម ដែលបានចុះបញ្ជីពន្ធដារ ចំពោះការទិញធាតុចូលផលិតកម្ម ដែលផលិតក្នុងស្រុក
- ផ្តល់ទិដ្ឋាការពិសេសរយៈពេល ៣ ឆ្នាំ សម្រាប់ការទិញ ឬ ជួលអចលនទ្រព្យរយៈពេលវែង ក្នុងខេត្តព្រះសីហនុ ដែលមានតម្លៃលើសពី ១០០ ០០០ ដុល្លារអាមេរិក ។ ប្រភេទនៃទិដ្ឋាការពិសេសនេះ ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក
- ពន្លឿនការត្រួតពិនិត្យគយ កែសម្រួល និង ផ្តល់សេវាល្អ ជូនដល់ភ្ញៀវទេសចរ និង វិនិយោគិន ទាំងនៅពេលមកដល់ ពេលស្នាក់នៅ និង ពេលត្រឡប់ទៅវិញ
- រៀបចំយុទ្ធនាការ "ទីក្រុងសុវត្ថិភាព", ព្រឹត្តិការណ៍ និង កម្មវិធីនានា ដើម្បីស្តារ និង ពង្រឹងកិត្តិនាមរបស់ខេត្តព្រះសីហនុ លើឆាកអន្តរជាតិ
- ពន្លឿនការអនុម័ត និង ប្រកាសដាក់ឱ្យប្រើប្រាស់ផែនការមេ ប្រែក្លាយខេត្តព្រះសីហនុជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ។

## គ. ការពង្រីកគម្រោងដែលមានស្រាប់

បន្ថែមពីលើអគារជាប់គាំង និង ការវិនិយោគជាទូទៅ, រាជរដ្ឋាភិបាលមានភាពចាំបាច់ក្នុងការលើក-ទឹកចិត្តឱ្យគម្រោង ដែលកំពុងតែវិនិយោគនៅកម្ពុជា ដែលមានបំណងចង់ពង្រីក ជាពិសេស ការពង្រីកគម្រោង និង ធុរកិច្ចក្នុងខេត្តព្រះសីហនុ តាមរយៈការដាក់ចេញនូវវិធានការដូចខាងក្រោម៖

- សម្រួលនីតិវិធី បែបបទ និង ការអនុញ្ញាតផ្សេងៗ សម្រាប់បម្រើដល់ការអនុវត្តគម្រោង ឬ សកម្មភាពពង្រីកការវិនិយោគ និង/ឬ ធុរកិច្ច
- ផ្តល់ការលើកទឹកចិត្ត និង ការអនុគ្រោះនានា ដូចជា ពន្ធអាករនាំចូល ពន្ធប៉ាតង់ ពន្ធលើផ្ទាំងផ្សព្វផ្សាយ និង ពន្ធកាត់ទុកលើការជួលអចលនទ្រព្យ ជាដើម ដល់សហគ្រាសដែលអនុវត្តគម្រោង ឬ សកម្មភាពពង្រីកការវិនិយោគ និង/ឬ ធុរកិច្ច
- គ.ល.គ ដែលស្នើសុំពង្រីក និង អនុវត្តសកម្មភាពវិនិយោគរបស់ខ្លួន ត្រូវទទួលបានការលើក-ទឹកចិត្តលើកលែងពន្ធលើប្រាក់ចំណូលនូវរយៈពេលជាក់លាក់ណាមួយ ទៅតាមប្រភេទក្រុមសកម្មភាពវិនិយោគនៃគម្រោងដើម ផ្អែកតាមសមមាត្រនៃអត្រាទុនពង្រីក ស្របតាមអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និង ត្រូវបានអនុញ្ញាតឱ្យយក

១៥០% គុណនឹងប្រាក់ចំណូលដែលត្រូវទទួលបានការលើកទឹកចិត្តលើកលែងពន្ធលើប្រាក់ចំណូល សម្រាប់ធ្វើជាមូលដ្ឋានក្នុងការគណនាពន្ធលើប្រាក់ចំណូល

- សហគ្រាសធុនតូច និង មធ្យម ដែលបានទទួលនូវការលើកទឹកចិត្តក្រោមអនុក្រឹត្យស្តីពីការលើកទឹកចិត្តផ្នែកពន្ធដារក្នុងវិស័យអាទិភាព ហើយស្នើសុំពង្រីក និង អនុវត្តសកម្មភាពធុរកិច្ចរបស់ខ្លួន ត្រូវទទួលបានការលើកទឹកចិត្តលើកលែងពន្ធលើប្រាក់ចំណូលរយៈពេល ៣ ឆ្នាំបន្ថែម ផ្អែកតាមសមមាត្រនៃអត្រាទុនពង្រីក និង អនុញ្ញាតឱ្យយក ១៥០% គុណនឹងប្រាក់ចំណូលដែលត្រូវទទួលបានការលើកទឹកចិត្តលើកលែងពន្ធលើប្រាក់ចំណូល សម្រាប់ធ្វើជាមូលដ្ឋានក្នុងការគណនាពន្ធលើប្រាក់ចំណូល
- សហគ្រាសដែលស្នើសុំពង្រីក និង អនុវត្តសកម្មភាពវិនិយោគ ឬ ធុរកិច្ចដទៃទៀត ត្រូវទទួលបានការលើកទឹកចិត្តលើកលែងពន្ធលើប្រាក់ចំណូលរយៈពេល ៣ ឆ្នាំ ផ្អែកតាមសមមាត្រនៃអត្រាទុនពង្រីក និង អនុញ្ញាតឱ្យយក ១៥០% គុណនឹងប្រាក់ចំណូលដែលត្រូវទទួលបានការលើកទឹកចិត្តលើកលែងពន្ធលើប្រាក់ចំណូល សម្រាប់ធ្វើជាមូលដ្ឋានក្នុងការគណនាពន្ធលើប្រាក់ចំណូល

គ.ល.គ, សហគ្រាសធុនតូច និង មធ្យម និង សហគ្រាសខាងលើ ត្រូវបំពេញតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- ការពង្រីកដើមទុនចាប់ពី ៣០% ឡើងនៃទុនវិនិយោគដែលបានអនុវត្តជាក់ស្តែងមុនពេលពង្រីក
- សហគ្រាសបានចុះបញ្ជីពន្ធដារ និង បានបំពេញកាតព្វកិច្ចចំពោះរដ្ឋ
- ការពង្រីកធ្វើឡើងក្រោមរូបភាពណាមួយដូចខាងក្រោម៖
  - ការពង្រីកផលិតកម្មដែលមានស្រាប់
  - ការពង្រីកតាមរយៈការធ្វើពិពិធកម្មមុខសញ្ញាផលិតកម្ម ដែលស្ថិតក្នុងសៃស្រឡាយផលិតផលជាមួយគ្នា
  - ការពង្រីកតាមរយៈការបំពាក់បច្ចេកវិទ្យាទំនើបថ្មីដែលលើកកម្ពស់ផលិតភាព ឬ ការពារបរិស្ថាន

ករណីការពង្រីកសកម្មភាពក្រោមរូបភាពផ្សេងទៀត ត្រូវមានការអនុញ្ញាតពីរាជរដ្ឋាភិបាល

- គ.ល.គ និង សហគ្រាសដែលស្នើសុំ និង អនុវត្តគម្រោង ឬ សកម្មភាពពង្រីកខាងលើ ត្រូវទទួលបានការលើកលែងប្រាក់រំដោះពន្ធលើប្រាក់ចំណូល ផ្អែកតាមសមមាត្រនៃអត្រាទុនពង្រីក និង ពន្ធអប្បបរមា ក្នុងរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល អាស្រ័យតាមប្រភេទគម្រោង ឬ សកម្មភាពពង្រីក

ការលើកលែងពន្ធលើប្រាក់ចំណូល ប្រាក់រំដោះពន្ធលើប្រាក់ចំណូល និង ពន្ធអប្បបរមាសម្រាប់សកម្មភាពពង្រីក ត្រូវគិតចាប់ពីពេលដែលសហគ្រាសទទួលបានចំណូលដំបូងពីសកម្មភាពពង្រីក ។

## ឃ. ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និង ការអភិវឌ្ឍតំបន់ឧស្សាហកម្ម

ដើម្បីអនុវត្តវិធានការខាងលើប្រកបដោយប្រសិទ្ធភាព, ការកសាងហេដ្ឋារចនាសម្ព័ន្ធបន្ថែម ដែលផ្សារភ្ជាប់ជាមួយនឹងការអភិវឌ្ឍឧស្សាហកម្ម នៅតែមានសារៈសំខាន់ និង មានភាពចាំបាច់ ដើម្បីបំពេញគ្នាទៅវិញទៅមក សម្រាប់ការស្តារ និង ការឈានហក់ឡើងនៃសេដ្ឋកិច្ច ក្នុងខេត្តព្រះសីហនុ ។

ក្នុងន័យនេះ, រាជរដ្ឋាភិបាលដាក់ចេញវិធានការ ដូចខាងក្រោម៖

- កំណត់អាទិភាព និង វិនិយោគលើគម្រោងហេដ្ឋារចនាសម្ព័ន្ធ ដែលចាំបាច់សម្រាប់គាំទ្រដល់ការអភិវឌ្ឍឧស្សាហកម្ម ការអភិវឌ្ឍទេសចរណ៍ និង ការទាក់ទាញការវិនិយោគ
- អភិវឌ្ឍតំបន់ឧស្សាហកម្ម និង សួនឧស្សាហកម្មធំៗ, ពិសេស ពង្រឹងតំបន់សេដ្ឋកិច្ចពិសេសដែលមានស្រាប់ ឱ្យឈានដល់កម្រិតស្តង់ដារអន្តរជាតិលើគ្រប់ទិដ្ឋភាព រួមមាន ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ, ការផ្គត់ផ្គង់អគ្គិសនី ទឹកស្អាត វត្ថុធាតុដើម និង ធាតុចូលផ្សេងៗ, កិច្ចសម្រួលការដឹកជញ្ជូន និង ពាណិជ្ជកម្ម, ការលើកទឹកចិត្ត និង វិធានការគាំទ្រផ្សេងទៀត
- សម្របសម្រួលក្នុងការអភិវឌ្ឍដីដែលមានសក្តានុពល (ដីកម្មសិទ្ធិរដ្ឋ ឬ ឯកជន) ដើម្បីប្រែក្លាយដីទាំងនេះ ទៅជាតំបន់ប្រមូលផ្តុំឧស្សាហកម្ម ឬ សហគ្រាស និង/ឬ តំបន់ទេសចរណ៍ដែលរាជរដ្ឋាភិបាលនឹងចូលរួមគាំទ្រផ្នែកគោលនយោបាយលើកទឹកចិត្ត, ការអនុគ្រោះ និង ហេដ្ឋារចនាសម្ព័ន្ធនានា
- អនុវត្តតំបន់សាកល្បងគំរូមួយ ឬ ច្រើន ដែលជាតំបន់សេដ្ឋកិច្ចពិសេស, តំបន់ទេសចរណ៍ពិសិដ្ឋ, តំបន់ពាណិជ្ជកម្មសេរី, តំបន់ប្រមូលផ្តុំឧស្សាហកម្ម ឬ ភណ្ឌាគារគយ ដើម្បីប្រមូលផ្តុំធនធាន និង ជំរុញការអភិវឌ្ឍឱ្យបានលឿន និង មានប្រសិទ្ធភាព ដែលអាចជ្រើសរើសចេញពីតំបន់ដែលត្រូវពង្រីកបន្ថែម, ឬ នៅស្ទឹងហាវ ឬ កន្លែងដទៃទៀត តាមរយៈកិច្ចសហការរវាងរដ្ឋ និង វិស័យឯកជន, ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរួម និង សកម្មភាពផ្សេងៗរួមគ្នា ។

## ៣. យន្តការអនុវត្ត តាមដាន ត្រួតពិនិត្យ និង វាយតម្លៃ

ប្រសិទ្ធភាព និង ភាពជោគជ័យ ក្នុងការអនុវត្ត **កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ ឆ្នាំ ២០២៤** ពឹងផ្អែកខ្លាំងលើយន្តការអនុវត្ត, តាមដាន, ត្រួតពិនិត្យ និង វាយតម្លៃ ប្រកបដោយឆន្ទៈនយោបាយមោះមុត និង ធនធានគ្រប់គ្រាន់ ។ កន្លងមក, រាជរដ្ឋាភិបាលបានបង្កើតក្រុមការងារអន្តរក្រសួង ដឹកនាំដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រោមឆ័ត្រគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីអនុវត្តវិធានការដោះស្រាយគម្រោងវិនិយោគជាប់គាំងក្នុងខេត្តព្រះសីហនុ ។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលនឹងបន្តប្រើប្រាស់យន្តការនៃក្រុមការងារនេះ ដើម្បីអនុវត្តនូវកម្មវិធីពិសេសនេះ និង បន្តអនុវត្តវិធានការដោះស្រាយគម្រោងវិនិយោគជាប់គាំង ដោយកែសម្រួលភារកិច្ច និង សមាសភាពឡើងវិញ ។ ក្រុមការងារអន្តរក្រសួងនេះ មានភារកិច្ច, តួនាទី និង សមាសភាព ដូចខាងក្រោម៖

**ទី១.** ក្រុមការងារមានឈ្មោះថា ក្រុមការងារជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ និង មានសិទ្ធិប្រើប្រាស់ត្រាក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់បំពេញភារកិច្ច ទាំងតាមទម្រង់ច្បាប់ដើម និង តាមប្រព័ន្ធអេឡិកត្រូនិក ។ ក្រុមការងារនេះមានភារកិច្ចដឹកនាំ, សម្របសម្រួល និង អនុវត្តកម្មវិធីពិសេសនេះ រួមទាំងវិធានការដោះស្រាយគម្រោងវិនិយោគជាប់គាំងក្នុងខេត្តព្រះសីហនុ ដោយដើរតួនាទីជា "ច្រកចេញចូលតែមួយ" ដែលមានសិទ្ធិពិនិត្យ, សម្រេច និង ផ្តល់លិខិតអនុញ្ញាត ឬ អាជ្ញាបណ្ណនានា ជាកញ្ចប់ទៅលើគម្រោងវិនិយោគ និង សកម្មភាពធុរកិច្ច, ស្នើសុំដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តចាំបាច់នានា តាមរយៈគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង អនុវត្តនូវកិច្ចការផ្សេងៗទៀត ពាក់ព័ន្ធកម្មវិធីពិសេសនេះ តាមការសម្រេចរបស់រាជរដ្ឋាភិបាល ។ រាល់គម្រោងវិនិយោគ និង សកម្មភាពធុរកិច្ច ដែលស្ថិតនៅក្រោមវិសាលភាពនៃកម្មវិធីពិសេសនេះ ត្រូវដាក់ស្នើមកក្រុមការងារនេះ ដើម្បីក្រុមការងារពិនិត្យ, វាយតម្លៃ និង ផ្តល់ការអនុម័ត ។

**ទី២.** ក្រុមការងារត្រូវមានសមាសភាពមកពីក្រសួង និង ស្ថាប័នពាក់ព័ន្ធ ដែលមានដូចជា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ក្រសួងទេសចរណ៍, ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់, ក្រសួងយុត្តិធម៌, ក្រសួងមហាផ្ទៃ, ក្រសួងពាណិជ្ជកម្ម, ក្រសួងសាធារណការ និង ដឹកជញ្ជូន, និង រដ្ឋបាលខេត្តព្រះសីហនុ ព្រមទាំងក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដែលទទួលបានប្រតិភូកម្ម ឬ មានសិទ្ធិសម្រេច ក្នុងនាមប្រធានក្រសួងស្ថាប័ន ។

**ទី៣.** ក្រុមការងារមានលេខាធិការដ្ឋានមួយជាសេនាធិការ និង មានធនធានហិរញ្ញវត្ថុ ក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ លេខាធិការដ្ឋានដើរតួនាទីសម្របសម្រួលផ្នែករដ្ឋបាលទាំងអស់ និង មានការិយាល័យនៅខេត្តព្រះសីហនុ និង រាជធានីភ្នំពេញ តាមការចាំបាច់ ។

**ទី៤.** ក្រុមការងារត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈនូវកម្មវិធីពិសេសនេះ ឱ្យបានទូលំទូលាយ, ធ្វើការពន្យល់ឱ្យបានច្បាស់ និង ត្រឹមត្រូវ, និង ផ្តល់សេវាបដិសណ្ឋារកិច្ច និង កិច្ចសហការល្អដល់វិនិយោគិន និង ធុរជន, ទាំងក្នុងប្រទេស និង ក្រៅប្រទេស ដើម្បីលើកកម្ពស់ការយល់ដឹង និង ទាក់ទាញការចូលរួមអនុវត្តពីកម្លាំងចលករសំខាន់ៗ ។

**ទី៥.** ក្រុមការងារត្រូវដាក់ចេញកម្មវិធីពង្រឹងសមត្ថភាពដល់ថ្នាក់ដឹកនាំ និង មន្ត្រីជំនាញ ព្រមទាំងអ្នកពាក់ព័ន្ធ ដោយផ្តោតលើការបំពេញភារកិច្ច, ការសម្របសម្រួល, ការផ្តល់សេវាដល់វិនិយោគិន និង ធុរជន, ការរៀបចំគម្រោង និង ការតាមដាន ត្រួតពិនិត្យ និង វាយតម្លៃ ដើម្បីផ្តល់សេវា និង អនុវត្តការងារប្រកបដោយគណនេយ្យភាព, តម្លាភាព និង ប្រសិទ្ធភាព ។

**ទី៦.** ក្រុមការងារត្រូវធ្វើការតាមដាន និង វាយតម្លៃ ការអនុវត្តកម្មវិធីពិសេសនេះ ដើម្បីដោះស្រាយបញ្ហាប្រឈម, ដាក់ចេញវិធានការកែតម្រូវ, វាស់វែងពីការខិតខំប្រឹងប្រែង និង វាយតម្លៃប្រសិទ្ធភាព និង លទ្ធផលនៃការអនុវត្តកម្មវិធីពិសេសនេះ ។ ក្នុងគោលបំណងឆ្លើយតបនឹងកម្មវត្ថុនេះ, ក្របខ័ណ្ឌអនុវត្តការងារនេះ ត្រូវបានរៀបចំតាមអភិក្រម "ជីវភាពនៃប្រព័ន្ធតួអង្គតែមួយ" ដែលមានសហប្រតិបត្តិការល្អ និង សង្គតិភាពជាមួយគ្នា, មានកិច្ចសម្របសម្រួលខ្ពស់ និង ការទទួលខុសត្រូវ, មានកិច្ចសហការល្អ និង ការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធ, និង មានការរៀបចំការត្រួតពិនិត្យលទ្ធផលជាប្រចាំ ។

**ទី៧.** ក្រុមការងារត្រូវរៀបចំរបាយការណ៍ ៣ ខែម្តង ជូនរាជរដ្ឋាភិបាល តាមរយៈគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ធ្វើរបាយការណ៍វាយតម្លៃការអនុវត្តកម្មវិធីពិសេសនេះជូនរាជរដ្ឋាភិបាល តាមរយៈគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៅខែ ធ្នូ ឆ្នាំ ២០២៤ ។

## ៤. សន្និដ្ឋាន

ជារួម, **កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ ឆ្នាំ ២០២៤** ត្រូវបានគិតគូររៀបចំឡើង ក្នុងបរិការណ៍ដែលស្ថានភាពសេដ្ឋកិច្ចជាទូទៅ ក្នុងសកលលោក, តំបន់ និង កម្ពុជាពុំទាន់មានលក្ខណៈប្រសើរឡើងវិញទាំងស្រុង, ការប្រកួតប្រជែងកាន់តែស្វិតស្វាញ និង ម៉្យាង, រាជរដ្ឋាភិបាលមានតម្រូវការចាំបាច់នៅចំពោះមុខ ក្នុងការជ្រើសរើសយកខេត្តព្រះសីហនុ ដែលមានសក្តានុពល និង មានមូលដ្ឋានឧស្សាហកម្ម និង ទេសចរណ៍ស្រាប់ សម្រាប់បង្កើនសម្ទុះ ឱ្យកាន់តែហក់ឡើង, ពិសេសប្រើប្រាស់ឱ្យអស់លទ្ធភាពនូវហេដ្ឋារចនាសម្ព័ន្ធ និង សមិទ្ធផល ដែលសម្រេចបានកន្លងមក ។

**កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តព្រះសីហនុ ឆ្នាំ ២០២៤** មានភាពទន់ភ្លន់ និង បត់បែនខ្ពស់ ដោយត្រូវបានចាត់ទុកថា "**ឯកសាររស់**" ដែលអាចនឹងកែសម្រួលបន្ថែមជាយថាហេតុ ក្នុងករណីចាំបាច់ ដើម្បីធានាសង្គតិភាព និង ការឆ្លើយតបទៅនឹងកាលៈទេសៈចំពោះមុខជាក់ស្តែង, ទាំងក្នុងប្រទេស, តំបន់ និង សកលលោក ។ ទន្ទឹមនេះ, ភាពជោគជ័យនៃការអនុវត្តកម្មវិធីពិសេសនេះ នឹងផ្តល់ជាមូលដ្ឋានដ៏មានសារៈសំខាន់ សម្រាប់ការបន្តរៀបចំរបៀបវារៈគោលនយោបាយអភិវឌ្ឍសង្គមសេដ្ឋកិច្ច, ជាពិសេស បទពិសោធន៍ល្អៗ និង មេរៀន សម្រាប់ការអនុវត្តផែនការមេ ដើម្បីអភិវឌ្ឍ និង ប្រែក្លាយខេត្តព្រះសីហនុ ទៅជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង និង អភិវឌ្ឍបណ្តាខេត្តជាប់ឆ្នេរសមុទ្រកម្ពុជា ជារបៀងសេដ្ឋកិច្ចពហុបំណង និង ប្រទាក់ក្រឡា ៕